ជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សម្តេច ឯកឧត្តមដែលមាននាមក្នុងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៧ ._** អនុក្រឹត្យនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២៩ អនក្រ.តត

## ស្តីពីការបង្វែរឥណទាន

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ /០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ចុះថ្ងៃទី២៥ខែធ្នូឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានចំណាយទៅតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០

- បានឃើញលិខិតលេខ ៧៧ អយក.ស្នរ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០០០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង និងចំណារបញ្ជូនលេខ ២៥ អយក.ប ចុះថ្ងៃទី០៧ ខែ មិនា ឆ្នាំ២០០០ របស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ ._ ត្រូវបានអនុញ្ញាតអោយបង្វែរឥណទានថវិកាចំនួន ៩៦.២០០.០០០រៀល ( កៅសិបប្រាំមួយលានពីររយពាន់រៀលគត់ ) ពីជំពូក ១០ ( ប្រាក់បៀវត្ស និងប្រាក់បំណាច់ ) ទៅជំពូក៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិង វប្បធម៌ ) របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តស្វាយរៀង នៃក្រសួងអប់រំ យុវជន និងកីឡា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដូចខាងក្រោម ៖

| ជំពូក | ឥណទានដើមឆ្នាំ | ការប្រែប្រួលឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|
| | | កើន | ថយ | |
| ១០ | ៥.១២២,០ | | ៩៦,២ | ៥.០២៥,៨ |
| ៣១ | ១០៦,០ | ៩៦,២ | | ២០២,២ |
| សរុប | ៥.២២៨,០ | ៩៦,២ | ៩៦,២ | ៥.២២៨,០ |

មាត្រា ២ ._ ឥណទានថវិកាក្នុងមាត្រា១ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តស្វាយរៀង នៃក្រសួងអប់រំយុវជន និងកីឡា សំរាប់ចំណាយឧបត្ថម្ភនិវត្តជនចំនួន ៨៨.៥២៦.៤៥០រៀល និងសំរាប់ចំណាយឧបត្ថម្ភគោលនយោបាយមន្ត្រីរាជការអរណោះភាព ចំនួន ៧.៦៧៣.៥៥០រៀល ។

មាត្រា ៣ ._ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ